សលាកប័ត្រព័ត៌មាន ៖ កម្រងឯកសារករណីសិក្សា ៖ សមាគមធាងត្នោត
រូបភាពរួម ៖ ការព្យួរសកម្មភាពរបស់ សមាគមធាងត្នោត ត្រូវបានមើលឃើញយ៉ាងច្បាស់ថាជាការបង្ក្រាបដ៏ទូលំទូលាយមកលើអង្គការមិនមែនរដ្ឋាភិបាល (អង្គការ) នៅកម្ពុជា និងត្រូវបានមើលឃើញថាជាភស្តុតាងនៃវិធីសាស្ត្រ ដែលរាជរដ្ឋាភិបាលកម្ពុជា (រដ្ឋាភិបាល) ទំនងនឹងអនុវត្តសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

សេចក្តីផ្តើម

អង្គការជាតិ និងអន្តរជាតិចំនួន ៤០ បានរួមគ្នាចេញនូវសេចក្តីថ្លែងការណ៍ចំណងជើងថា "ថ្ងៃនេះ អនាគតរបស់លទ្ធិ-ប្រជាធិបតេយ្យស្ថិតនៅលើផ្លូវបំបែក" ដែលរៀបរាប់ពីការព្យួរសកម្មភាពរបស់សមាគមធាងត្នោត ជាអង្គការក្នុងស្រុកមួយ នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១១។ ការព្យួរសកម្មភាពនេះកើតឡើង បន្ទាប់ពីមានការប៉ាន់ស្មានរបស់ក្រុមសារព័ត៌មាន និងក្រុមអង្គការសង្គមស៊ីវិលថាតើរដ្ឋាភិបាលនឹងប្រើប្រាស់ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដោយរបៀបណា ប្រសិនច្បាប់នោះនឹងត្រូវបានអនុម័តក្នុងទម្រង់បច្ចុប្បន្ន ឬទម្រង់ណាមួយដែលអាចជាហេតុផលសម្រាប់ប្រឆាំងនឹងអង្គការដែលរិះគន់គោលនយោបាយ និងផលប្រយោជន៍របស់រដ្ឋាភិបាល។ សលាកប័ត្រព័ត៌មាននេះ នឹងពិនិត្យមើលស្ថានភាពជុំវិញការព្យួរសកម្មភាពរបស់ សមាគមធាងត្នោត និងពិនិត្យលើមូលដ្ឋានគតិយុត្តនៅពីក្រោយសកម្មភាពនេះ។ សលាកប័ត្រព័ត៌មាននេះបានតាក់តែងឡើងដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

តើសមាគមធាងត្នោតជានរណា?

សមាគមធាងត្នោត ត្រូវបានបង្កើតក្នុងឆ្នាំ២០០៥ ដោយមានបេសកកម្មច្បាស់លាស់ក្នុងការផ្តល់ជំនួយបច្ចេកទេសពាក់ព័ន្ធនឹងបញ្ហាលំនៅស្ថាន និងហេដ្ឋារចនាសម្ព័ន្ធ និងបង្កើតការពិភាក្សា និងលើកកម្ពស់ការយល់ដឹងពីបញ្ហាក្នុងទីក្រុង។ រហូតមកទល់ពេលព្យួរសកម្មភាព សមាគមធាងត្នោតមានបុគ្គលិកចំនួន ១៣នាក់ បុគ្គលិកអន្តរជាតិចំនួន ២ និងមានបុគ្គលិកហាត់ការ និងអ្នកស្ម័គ្រចិត្តមួយចំនួន ហើយមានការិយាល័យនៅរាជធានីភ្នំពេញ និងខេត្តកំពត។ ក្នុងរយៈពេលថ្មីៗ សមាគមធាងត្នោត ធ្វើការតាមដានយ៉ាងខ្លាំងផ្តោតលើ គម្រោងអភិវឌ្ឍធំៗ ចំនួន២ ដែលបណ្តាលឲ្យ និងអាចបណ្តាលឲ្យមានការបណ្តេញចេញ និងជម្លៀសប្រជាពលរដ្ឋខ្មែររាប់ពាន់គ្រួសារ ដូចជា ករណីបឹងកក់ ដែលជាការអភិវឌ្ឍន៍រួមគ្នារវាងសមាជិកព្រឹទ្ធសភាពីគណបក្សប្រជាជនកម្ពុជា និងក្រុមហ៊ុនចិនដែលអាចប៉ះពាល់ដល់ប្រជាពលរដ្ឋចំនួន ៤,០០០គ្រួសារនៅទីក្រុងភ្នំពេញ និងគម្រោងស្ពារ និងជួសជុលផ្លូវរថភ្លើង ដើម្បីជួសជុលផ្លូវរថភ្លើងភ្ជាប់ពីភ្នំពេញ ទៅប្រទេសថៃ ដែលរំពឹងថាអាចប៉ះពាល់ដល់ប្រជាពលរដ្ឋប្រហែលជា ៥,០០០ គ្រួសារផងដែរ។ ស្ថានទៅកាន់សន្តិភាពកម្ពុជា ជាអង្គការចុះបញ្ជីនៅសហរដ្ឋអាមេរិក បានធ្វើការយ៉ាងជិតស្និទ្ធជាមួយ សមាគមធាងត្នោត លើការតាមដានគម្រោងទាំងនេះ។ គម្រោងស្ពារ និងជួសជុលផ្លូវរថភ្លើង គឺជាគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធថ្នាក់ជាតិដ៏សំខាន់មួយ ដែលផ្តល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ី កម្មវិធីជំនួយអូស្ត្រាលីសម្រាប់ការអភិវឌ្ឍន៍ និងរដ្ឋាភិបាលកម្ពុជា។

ហេតុអ្វីបានជាសមាគមធាងត្នោតត្រូវបានព្យួរសកម្មភាព?

សមាគមធាងត្នោត ត្រូវព្យួរសកម្មភាព រយៈពេល៥ខែ ចាប់ពី ថ្ងៃទី១ ខែសីហា ឆ្នាំ២០១១ ដោយក្រសួងមហាផ្ទៃ។ ការព្យួរសកម្មភាពនេះ កើតឡើងរយៈពេលមួយខែក្រោយពី សមាគមធាងត្នោត ចេញផ្សាយរបាយការណ៍ នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ចំណងជើងថា "ការជួសជុលផ្លូវរថភ្លើងកម្ពុជា ៖ ការប្រៀបធៀបទិន្នន័យនៅនឹងទីតាំង" ដែលរាយការណ៍ពីរបកគំហើញនៃ "ការបន្តយតម្លៃនៃប្រភេទរចនាសម្ព័ន្ធជាប្រព័ន្ធ ដើម្បីឲ្យមានការផ្តល់សំណងទាបជាងមុន" ដែលជំពាក់ម្ចាស់ផ្ទះដែលរងផលប៉ះពាល់ដោយការជួសជុលផ្លូវរថភ្លើង ក៏ដូចជា "ចំនួនផ្ទះសម្បែងដែលរងផលប៉ះពាល់មានចំនួនកើនឡើង" ច្រើនជាងរបាយការណ៍របស់រដ្ឋ។ ក្រសួងមហាផ្ទៃសបានអះអាងចំពោះការព្យួរសកម្មភាពនេះ ថាសមាគមធាងត្នោតខកខានក្នុងការបញ្ជាក់ពីរចនាសម្ព័ន្ធគ្រប់គ្រង និងផ្លាស់ប្តូរលក្ខន្តិក:ដែលបង្គាប់ដោយក្រសួងមហាផ្ទៃ ក្នុងកិច្ចប្រជុំកាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១១។ បើទោះបីជា សមាគមធាងត្នោតមិនត្រឹមតែបានធ្វើតាមការណែនាំរបស់ក្រសួងមហាផ្ទៃទាន់តាមពេលវេលាកំណត់នោះទេ តែក៏មិនមានច្បាប់បច្ចុប្បន្នណាដែលចែងពីមូលដ្ឋាននៃការព្យួរសកម្មភាពរបស់សមាគមធាងត្នោតដោយ

ផ្អែកលើការខកខានបំពេញតាមនីតិវិធីនោះដែរ។ អង្គការនៅកម្ពុជា បាននិយាយថាការព្យួរសកម្មភាពតាមអំពើចិត្តបែបនេះ បង្ហាញពីការប៉ុនប៉ងរបស់រដ្ឋាភិបាលដើម្បីអនុម័តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ជាច្បាប់ដែលអ្នកវិភាគនិយាយថានឹងត្រូវប្រើប្រាស់ដើម្បីធ្វើឲ្យសកម្មភាពទប់ស្កាត់នឹងអង្គការដែលរិះគន់រដ្ឋាភិបាល ក្លាយជាទង្វើស្របច្បាប់។

កាលពីថ្ងៃទី ១៣ ខែសីហា ក្រសួងមហាផ្ទៃបានផ្តល់ការពន្យល់មួយទៀត ស្តីពីការព្យួរសកម្មភាពរបស់សមាគមធាងត្នោត ហើយមានចំណុចមួយ ដែលត្រូវបានស្នើដោយអ្នកសង្កេតការណ៍ គឺប្រហាក់ប្រហែលនឹងការប៉ុនប៉ងដ៏ពិតប្រាកដនៃចលនាប្រឆាំងនឹងអង្គការនេះ។ ក្នុងសេចក្តីថ្លែងការណ៍ដាក់នៅលើគេហទំព័ររបស់ក្រសួងមហាផ្ទៃ នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ ២០១១ និងការដកស្រង់សម្តីចេញពីសារព័ត៌មាន ឌឹ ខេមបូឌា ដេលី នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១ ដែលបាននិយាយថា សមាគមធាងត្នោត ប្រឆាំងនឹងការស្តារ និងជួសជុលផ្លូវរថភ្លើងរវាងកម្ពុជានិងថៃ ហើយដូច្នេះព្យាយាមរារាំងមិនឲ្យរដ្ឋាភិបាលធ្វើការអភិវឌ្ឍប្រទេសជាតិ។ សេចក្តីថ្លែងការណ៍បានបញ្ជាក់ថា "សមាគមធាងត្នោតធ្វើសកម្មភាព និងញុះញង់ឲ្យប្រជាពលរដ្ឋប្រឆាំងនឹងការអភិវឌ្ឍន៍ប្រទេសរបស់រដ្ឋាភិបាល នៅខេត្តកំពត និងភ្នំពេញដើម្បីធ្វើឲ្យដៃគូអភិវឌ្ឍព្យួរ ឬបញ្ឈប់គម្រោង" ។ ដោយសារការញុះញង់ ជាបទល្មើសឧក្រិដ្ឋយោងតាមមាត្រា ៤៩៥ ក្នុងក្រមព្រហ្មទណ្ឌ មូលដ្ឋាននៃការព្យួរសកម្មភាពនេះត្រូវបានចាត់ទុកថាជាកំហុសព្រហ្មទណ្ឌ បើទោះបីជា ករណីនេះមិនត្រូវបានវិនិច្ឆយដោយស្ថាប័នតុលាការដែលមិនលម្អៀងណាមួយនៅឡើយ។

បញ្ហាបានរីករាលដាល

នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ ក្រសួងមហាផ្ទៃបានអញ្ជើញ អង្គការស្តានទៅកាន់សន្តិភាពកម្ពុជា និងបណ្តាញអង្គការ គឺវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា មកជួបក្នុងកិច្ចប្រជុំ ដែលក្រសួងមហាផ្ទៃបានចោទប្រកាន់អង្គការទាំងពីរថាបានលើកយកនូវអំណះអំណាងមិនពិត និងមិនយុត្តិធម៌ពាក់ព័ន្ធនឹងការស្លាប់របស់ក្មេងពីរនាក់ក្នុងគ្រួសារដែលទទួលរងផលប៉ះពាល់ដោយគម្រោងស្តារ និងជួសជុលផ្លូវរថភ្លើង នៅនឹងកន្លែង។ ក្រសួងមហាផ្ទៃបានចោទប្រកាន់អង្គការទាំងនេះពីបទញុះញង់ក្រុមគ្រួសារឲ្យប្រឆាំង នឹងការជួសជុលប្រព័ន្ធផ្លូវរថភ្លើងនៅកម្ពុជា បង្គាប់ឲ្យអង្គការក្រៅរដ្ឋាភិបាល "កែតម្រូវ" ការងាររបស់ពួកគេ។ ម្យ៉ាងវិញទៀត ក្រសួងមហាផ្ទៃបានដាក់នូវការព្រមានស្រដៀងគ្នានេះ មកលើក្រុមការងារសិទ្ធិលំនៅស្ថាន ដែលជាបណ្តាញអង្គការមួយទៀត។ បណ្តឹងរបស់ក្រសួងមហាផ្ទៃពាក់ព័ន្ធនឹងលិខិតចុះថ្ងៃទី២១ ខែតុលា ឆ្នាំ ២០១០ សរសេរដោយសមាគមធាងត្នោត ស្ពានទៅកាន់សន្តិភាពកម្ពុជា វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា និងក្រុមការងារសិទ្ធិលំនៅស្ថាន ដែលអង្គការបានលើកយកបញ្ហាដែលមានក្នុងគម្រោងផ្លូវរថភ្លើង ក៏ដូចជា ទាក់ទាញចំណាប់អារម្មណ៍មកលើការស្លាប់របស់ក្មេងនៅទីតាំងរុះរើ និងបង្ហាញថាទីតាំងនេះខ្វះខាតនូវសេវាកម្មជាមូលដ្ឋាន។

កាលពីថ្ងៃទី១៩ ខែកញ្ញា ភ្នាក់ងារសារព័ត៌មានអាល្លឺម៉ង់ និងអាស៊ីថែមស៍អនឡាញ បានបោះពុម្ពផ្សាយអត្ថបទស្តីពីលិខិតចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ សរសេរដោយ លោកឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លោក គាត ឈន់ ជូន លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។ ក្នុងលិខិត រដ្ឋមន្ត្រី បានស្នើសុំឲ្យចាត់ "វិធានការបន្ទាន់" ដើម្បីបញ្ឈប់សកម្មភាពរបស់អង្គការពីរដែលបានចារយ៉ាងច្បាស់លាស់ក្នុងលិខិតនេះគឺ សមាគមធាងត្នោត និងស្ពានទៅកាន់សន្តិភាពកម្ពុជា និងដើម្បី "ចាត់ភាពស្របច្បាប់របស់អង្គការទាំងពីរជាមោឃៈ"។ លោករដ្ឋមន្ត្រី បន្តសរសេរថា ៖ "ខ្ញុំចង់សំណូមពរឲ្យគណៈរដ្ឋមន្ត្រីពិនិត្យឡើងវិញ និងអនុវត្តសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលឲ្យឆាប់រហ័ស" ។ លិខិតនេះបានសរសេរ និងផ្ញើជូនលោកនាយករដ្ឋមន្ត្រីរយៈពេលមួយខែមុនពេលការព្យួរសកម្មភាពរបស់ សមាគមធាងត្នោត និងការបញ្ជូនសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលទៅកាន់គណៈរដ្ឋមន្ត្រី។ ស្របពេលជាមួយគ្នា មានអត្ថបទមួយត្រូវបានបោះពុម្ពផ្សាយដោយ សារព័ត៌មានភ្នំពេញប៉ុស្ត៍ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១ បញ្ជាក់ថានាយករដ្ឋមន្ត្រី ហ៊ុន សែន ត្រូវបានគេចោទថាយល់ព្រមតាមអនុសាសន៍របស់ លោករដ្ឋមន្ត្រី គាត ឈន់ ថាអង្គការបរទេសមិនគួរត្រូវបានអនុញ្ញាតឲ្យធ្វើសកម្មភាពតស៊ូមតិក្នុងព្រះរាជាណាចក្រ និងបានណែនាំឲ្យអង្គការក្នុងស្រុកមិនអាចអនុញ្ញាតបុគ្គលិកបរទេសធ្វើការតស៊ូមតិនោះទេ។ ភ្នំពេញប៉ុស្ត៍ បានបញ្ជាក់បន្ថែមថាលោកនាយករដ្ឋមន្ត្រីទទួលយកនូវអនុសាសន៍បន្ថែមទៀតដែលថាគណៈរដ្ឋមន្ត្រីគួរតែអនុម័ត និងអនុវត្តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលឲ្យបានលឿន។

សេចក្តីសន្និដ្ឋាន

ការព្យួរសកម្មភាពរបស់សមាគមធាងត្នោត របស់ក្រសួងមហាផ្ទៃ គឺមិនអនុលោមតាមច្បាប់ដែលចូលជាធរមានណាមួយនៅកម្ពុជានោះទេ ហើយក៏ផ្ទុយពីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាច្រកម្ពុជា (រដ្ឋធម្មនុញ្ញ) ផងដែរ។ មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ បានចែងពីសេរីភាពបញ្ចេញមតិ និងសេរីភាពនៃការប្រមូលផ្តុំ ឯមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញចែងថាប្រជាពលរដ្ឋខ្មែរទាំងអស់ "មានសិទ្ធបង្កើតសមាគម និងគណបក្សនយោបាយ" ចំណែកមាត្រា ៣៥ ក៏បានចែងពីសិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរទាំងអស់ "ក្នុងការចូលរួមយ៉ាងសកម្ម ក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ" ។ ម្យ៉ាងវិញទៀត មាត្រា ២០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា ២២ ក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានចែងពីសេរីភាពក្នុងការបង្កើតសមាគម ហើយមាត្រា ១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏បានចែងពីសេរីភាពបញ្ចេញមតិផងដែរ។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គឺជាផ្នែកមួយនៃច្បាប់កម្ពុជាតាមរយៈមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ។

ការព្យួរសកម្មភាពរបស់ សមាគមធាងត្នោត ផ្តល់ភស្តុតាងគ្រប់គ្រាន់ថា រដ្ឋាភិបាលកំពុងតែបង្ក្រាបអ្នកការពារសិទ្ធិមនុស្ស និងអង្គការសង្គមស៊ីវិលនៅកម្ពុជាដែលបានរិះគន់រដ្ឋាភិបាល ឬគោលនយោបាយរបស់រដ្ឋាភិបាល។ តាមការរៀបរាប់ខាងលើ ការព្យួរសកម្មភាពរបស់ សមាគមធាងត្នោត គឺគ្មានមូលដ្ឋានគតិយុត្តនោះទេ។ ប្រសិនបើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលត្រូវបានអនុម័ត នឹងមានការភ័យខ្លាចថាច្បាប់នេះអាចអនុញ្ញាតឲ្យរដ្ឋាភិបាលចាត់វិធានការស្របច្បាប់ដើម្បីចាត់ការជាមួយក្រុមអង្គការទាំងនេះ។

ព័ត៌មានបន្ថែមសូមទាក់ទង លោក អ៊ូ វីរៈ តាមរយៈ (ទូរស័ព្ទ ៖ +៨៥៥ (០)១២ ៤០ ៤០ ៥១ ឬអ៊ីម៉ែល ouvirak@cchrcambodia.org**។**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

CC BY NC SA